ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ...................

# សេចក្តីប្រកាសព័ត៌មាន
# អ្នកនាំពាក្យក្រសួងការពារជាតិ

នៅវេលាម៉ោង១៥៖៣០នាទីរសៀល ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នឹងអញ្ជើញជាអធិបតីភាព ក្នុងពិធីទទួលដំណើរមាតុភូមិនិវត្តន៍ របស់កងកម្លាំងរក្សាសន្តិភាព ដែលបានបញ្ចប់បេសកកម្ម នៅសាធារណរដ្ឋម៉ាលី និងស៊ូដង់ខាងត្បូង។

ពិធីនេះ នឹងរៀបចំឡើង នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ ក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន តំណាងអង្គការសហប្រជាជាតិ ភ្ញៀវជាតិ-អន្តរជាតិ និងបងប្អូនអ្នកសារព័ត៌មាន ផងដែរ។

កងកម្លាំងរក្សាសន្តិភាពកម្ពុជា ដែលធ្វើមាតុភូមិនិវត្តន៍នាពេលនេះរួមមាន៖ កងវិស្វកម្មព្រលានយន្តហោះលេខ១៨៩ ពីប្រទេសម៉ាលី ចំនួន១៦៥រូប កងកម្ទេចគ្រាប់មិនទាន់ផ្ទុះ លេខ១២៣ ពីប្រទេសម៉ាលី ចំនួន ១៤៤រូប និងកងរាជអាវុធហត្ថលេខ៦១៨ ពីសាធារណរដ្ឋស៊ូដង់ខាងត្បូង ចំនួន៧៣រូប៕

ថ្ងៃសុក្រ ៨កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
នៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨